# កាលពីតាកេសរមាលាបញ្ជាឱ្យទាសីចាប់ចៅស្រទបចេក




សព្វថ្ងៃទៀងតែ លង់លុះដល់ខែ ចេត្រចូលឆ្នាំថ្មី
អស់មនុស្សស្រើបស្រុស ទាំងប្រុសទាំងស្រី ជ្រួលជ្រើមឃ្លាតខ្ចី
យកកាសយកប្រាក់។

ទិញខៀនក្រមា ទិញទេសព្រៃផ្កា មកជ្រលក់ល័ក្ត
ក្រហមខៀវលឿង តាមតែចិត្តស្ម័គ្រ ខ្លះខ្មៅកក្លាក់
ក្រមាស៊ីខ្ចី។

ខ្លះស្លៀកសំពត់ បារាំងសែសសុទ្ធ ពាក់អាវសៀមថ្មី
ដៃកោងទង្គះ ល្អល្អះចុះដី នាំគ្នាទាត់សី
សើចសប្បាយមីរ។

ស្រីខ្លះខ្លួនខ្មៅ លាបប្រេងប្រោះម្សៅ ប្រលាក់ឈ្លក់ឈ្លី
មើលទៅកញ្ចក់ សិតសក់វ៉ែកវី ចាប់ក្រមាស៊ី
ដណ្តប់គ្រលំ។

ខ្លះកាត់សក់ថ្មី ស្អាងខ្លួនពិសី ដោមដាក់កន្ទំ
ស្លៀកហូលចំប្រប់ ដណ្តប់ផាហ៊ុម ចុះដើរនិយម
និយាយលងលេង។

ពួកក្មេងតូចៗ លេងឈូងហក់ហួច ប្រលូកប្រឡែង
លេងគោះពញ្ជាក់ លេងលាក់កន្សែង លេងចាប់កូនខ្លែង
លេងលោតអន្ទាក់។

ឯអង្គអាចារ្យ មានចិត្តមេត្តា ពង្សពោធិចក្រ
ប្រាប់ទៅភរិយា ថាឯងយកប្រាក់ ស្ទឹងបានមួយកាក់
ឱ្យស្រទបចេករ៉ា។

ពេលចូលឆ្នាំថ្មី គេលេងបីថ្ងៃ ច្នេះតាមចិត្តអា
ទោះឆ្ងាយទោះជិត កុំគិតឡើយណា លេងឱ្យសុខា
សមចិត្តចៅនែ។

ស្រទបចេកឆ្លើយថ្កាន ថាលោកឱ្យទាន ខ្ញុំបាទអរគ្រៃ
តែខ្ញុំពុំលេង ដោយល្បែងឡើយនែ ទុកទិញចំណី
សែនជូនខ្មោចម្តាយ។

*****





កេសរមាលា យល់គូសង្សារ ដើរមកពីឆ្ងាយ
ខំស្រែកគួរសម សូមអ្នកមកអោយ ទំនិញទាំងឡាយ
ខ្ញុំមានមិនខ្វះ។

ស្រទបចេកចៅ ពួនាងស្រែកហៅ ខំស្រូតរូតរះ
ស្រាវជើងញ័រញាប់ ប្រញាប់ពេកណាស់ ប្រឹងរត់ផុតផ្ទះ
នៃនាងឆោមឆាយ។

ឯនាងធីតា យង់យល់ជេដ្ឋា មិនមៀងមើលអាយ
គ្មានស្តាយគ្មានស្តាប់ ពាក្យពេចន៍និយាយ នួននាងឆោមឆាយ
ហៅអស់ទាសី។

ថាបងរាល់គ្នា ចង់ឱ្យជន្មា ប្អូនរស់នៅនៃ
មានតែប្រព្រឹត្ត តាមពាក្យប្អូនស្តី នោះទើបប្អូនស្រី
គង់ជីវិតនៅ។

ប្អូនចង់ប្រើបង ចាប់គេនោះផង ទៅចាប់ឥឡូវ
ឱ្យបានដូចចិត្ត កុំគិតខុសត្រូវ ធ្វើម្តេចឥឡូវ
ចាប់ឱ្យបានឆាប់។

ទាសីឃ្មាតខ្មី រៀបខ្លួនទីទៃ ប្រញិបប្រញាប់
ចងពុងពាតបា ភ្លៀវក្លាចំណាប់ ចំណង់ចង់ចាប់
ឱ្យបានដឹងការណ៍។

នាងខ្លះកំប្លែង ស្រដីឡកលេង នឹងអស់គ្គីគ្នា
ថាវើយខំឡើង អស់យើងរាល់គ្នា ម៉េចៗខំការ
ប្រយ័ត្នតែដោះ។

ខ្លួនយើងក្រមុំ ឯប្រុសឧត្តម គាត់ក៏កំលោះ
តែភ្លាត់ចំណាប់ ចាប់ឥតស្រណោះ ច្របាច់ខ្ទូចអស់
នៃវើយរាល់គ្នា។

ថាស្រេចពុំលង់ ឡើយចេញចាំប្រុង សងខាងមាគ៌ា
ម្ខាងបួន ម្ខាងបួន មាំមួនមហិមា ឯនាងធីតា
សឹងចាំរំពៃ។

ពន្លកជិនស្រី អ្នកទិញចំណី បានហើយវិលវៃ
កាន់នំកាន់នែក ជៀតជ្រែកពេញដៃ ដើរដល់ទីមនៃ
នាងនាថកល្យាណ។



យង់យល់ប្រុសមិត្ត នាងសែនអាណិត ពេកពន់ប្រមាណ
ស្មើរខ្លោចប្រមាត់ ចិត្តសោតរំខាន ស្រយុតអង្គប្រាណ
ស្រក់ទឹកនេត្រា។

តែខំស្រែកប្រាប់ ឱ្យទាសីចាប់ ប្រាណប្រុសសង្សារ
ថាហ៏!គ្នាយើង ឆាប់ឡើងរួសរ៉ា ចាប់មនុស្សនេះណា៎
ឱ្យបានកុំលែង។

ទាសីសោតស្តាប់ ស្ទុះព្រមចូលចាប់ ប្រលូកប្រឡែង
រញ៉ើករញ៉ៃ ទាញដៃជញ្ជែង ប្រយ័ត្នប្រយែង
ក្រែងរួចរត់បាត់។

នាងខ្លះស្រែកថា ប្រយ័ត្នចង្កា ក្រែងជួនជាទាត់
នាងខ្លះសោតឆ្លើយ ហងអើយកុំមាត់ កុំនាំអាទីគាត់
ក្រែងឡើងដោយដៃ។

ស្រទបចេកឆ្លើយ ថាឱនាងអើយ រូបខ្ញុំនេះនៃ
ពុំដឹងខ្លួនប្រាណ ជាមានទោសពៃរ៍ មកចាប់រញ៉ៃ
តើទោសបទណា។

ទាសីពុំស្តាប់ រឹងជាព្រួតចាប់ រួតរឹតកាយា
នំសោតខ្វាយខ្វាត់ ជ្រុះបាត់សោះសា អ្នកខំស្រែកថា
ជ្រុះនំអស់ហើយ។

នាងស្រែកទៅថ្កាន ថាចាប់ឱ្យបាន កុំឱ្យរួចឡើយ
អ្នកផ្សារផ្អូកផ្អើល មកមើលជាត្រើយ ចូលជិតបង្អើយ
ដណ្តឹងសួរថា។

ចាប់ពីហេតុអ្វី ទើបនាងស្រដី ក្លាយក្លែងទៅថា
មនុស្សនេះចិត្តធំ លួចខ្ញុំឯងណា ហើយរត់ទៅផ្សារ
គេចបាត់ពីថ្ងៃ។

ព្រឹញមិញដើរមក៏ ឯងអាត់តែវរ រកទិញអាវស្បៃ
ដាក់ប្រាក់ទាំងថង់ នៅត្រង់នេះនៃ ពុំបានជាគៃ
ជាគិតយ៉ាងណា។

ស្រាប់តែចូលមក លបលួចឆក់យក ទៅបាត់សោះសា
ខ្ញុំឱ្យទៅតាម គេចភ្លាមចូលផ្សារ ឥឡូវទេព្ភា
នាំមកឱ្យទាន។

នែ៎រើយទាញឡើង ចាប់ដៃចាប់ជើង ឱ្យខ្ជាប់នាំថ្កាន
ទៅឱ្យឆាប់ខ្មី កាត់ក្ដីប្រមាណ ស្រទបចេកបាន
ឮហើយភិតភ័យ។

ថាឱអ្នកអើយ ខ្ញុំមិនលួចឡើយ ណា៎អ្នកម្ចាស់ថ្លៃ
សូមអ្នកសន្ដោស ប្រោសប្រាណប្រណី កុំយកទោសពៃរ៍
អាណិតខ្ញុំផង។

នាងស្ដាប់ហើយណា អាណិតសង្សារ ពេកពន់កន្លង
កន្លែងខ្លោចផ្សា ឱរានួនល្អង ទឹកនេត្រធ្លាក់ផង
អន្លាមសោះសា។

ខំតែអាចអត់ ប្រាណប្រឹងសង្កត់ បំបាត់ទុក្ខា
ស្រែកប្រាប់ទាសី ប្រាំបីនាក់ណា ឱ្យនាំយាត្រា
ចរចូលក្នុងផ្ទះ។

**កវី យស ឥន**



